**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ២៤ អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការតំលើងការិយាល័យអប់រំកាយ និង កីឡាសិស្ស-និស្សិត ទៅជានាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១/អនក្រ/បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងអប់រំ យុវជន និង កីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

## ស ំ រេ ច

**មាត្រា ១ :**

ត្រូវបានតំលើងការិយាល័យអប់រំកាយ និង កីឡាសិស្ស-និស្សិត អោយទៅជានាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត ចំណុះអគ្គនាយកដ្ឋាន យុវជន និង កីឡា នៃក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ២ :

នាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត មានភារកិច្ច ÷

- គ្រប់គ្រងការងារអប់រំកាយ និង កីឡា ក្នុងជួរសិស្ស-និស្សិត គ្រប់គ្រឹះស្ថានសិក្សា
- បំផុស និង អភិវឌ្ឍសកម្មភាពអប់រំកាយ និង កីឡា តាមគ្រឹះស្ថានសិក្សា ក្នុង និង ក្រៅម៉ោងសិក្សា និងជំរុញសកម្មភាពសហព័ន្ធកីឡាសិស្ស-និស្សិត ដើម្បីចូលរួមប្រកួតលើឆាកអន្តរជាតិ
- រៀបចំកម្មវិធីសិក្សាមុខវិជ្ជា អប់រំកាយ និង កីឡា ហើយបញ្ចូលមុខវិជ្ជានេះ ទៅក្នុងការប្រលងនានា
- រៀបចំការប្រកួតកីឡា សិស្ស-និស្សិត និង ធ្វើអធិការកិច្ចលើមុខវិជ្ជា អប់រំកាយ និង កីឡា តាមគ្រប់ភូមិសិក្សា ។

មាត្រា ៣ :

នាយកដ្ឋានអប់រំកាយ និង កីឡាសិស្ស-និស្សិត ដែលដឹកនាំការងារដោយ ប្រធាន មួយរូប និង អនុប្រធាន មួយចំនួនជាជំនួយការ តាមការចាំបាច់ ។

មាត្រា ៤ :

ភារកិច្ចជាក់ស្តែង និង រចនាសម្ព័ន្ធរបស់ នាយកដ្ឋានអប់រំកាយ និង កីឡា សិស្ស-និស្សិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

មាត្រា ៥ :

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួង អប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ.